# បទបង្ហាញស្តីពី «ការគ្រប់គ្រង GDCC »
# ឈៀង យ៉ាណារ៉ា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
# កិច្ចប្រជុំលើកទី ១៨
# គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍
# ភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១

សូមគោរពឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាននៃកិច្ចប្រជុំ GDCC
លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក

១- ខ្ញុំសូមសំដែងអំណរគុណឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានកិច្ចប្រជុំ GDCC ដែលបានផ្តល់ឱកាសសម្រាប់ឱ្យខ្ញុំបកស្រាយដោយសង្ខេបនៅក្នុងកិច្ចប្រជុំលើកនេះ អំពីកិច្ចពិភាក្សាថ្មីៗកន្លងមកដែលពាក់ព័ន្ធនឹងការគ្រប់គ្រងកិច្ចប្រជុំGDCC សំដៅបង្កើនប្រសិទ្ធភាព ។ ខ្ញុំមានកិត្តយស ក្នុងឋានៈជាប្រធានលេខាធិការដ្ឋាននៃ GDCC ដែលមានភារកិច្ចទទួលត្រៀមរៀបចំ និងសម្របសម្រួលកិច្ចប្រជុំប្រភេទនេះចាប់តាំងពីចុងឆ្នាំ២០០៤មក ។ រហូតមកដល់ពេលនេះ ទម្រង់នៃកិច្ចប្រជុំនេះមានការផ្លាស់ប្តូរខាងគុណភាពជាច្រើន ។ ជាការពិតណាស់ ភាពជាដៃគូរបស់យើងមានការវិវត្តន៍ ហើយបន្តវិវត្តន៍ទៅមុខទៀត ដើម្បីស្វែងរកកាលានុវត្តភាព និងបញ្ហាប្រឈមនានាសម្រាប់អភិវឌ្ឍកម្ពុជា ។ ក្នុងឋានៈជាប្រធានលេខាធិការដ្ឋាននៃ GDCC ខ្ញុំបានផ្តោតការយកចិត្តទុកដាក់ទៅលើយន្តការនេះ និងក៏បានយល់ច្បាស់អំពីតម្រូវការនៃការពិនិត្យជាប្រចាំសម្រាប់បង្កើនប្រសិទ្ធភាពនៃយន្តការពិគ្រោះយោបល់របស់យើង ។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក

២- សេចក្តីព្រាងឯកសារស្តីពីការគ្រប់គ្រងកិច្ចប្រជុំGDCC ត្រូវបានចែកជូនគ្រប់សមាជិកនៃGDCC កាលពីដើមខែមិនា ឆ្នាំ២០១១ ហើយឯកសារសង្ខេបចំនួនមួយទំព័រក៏ត្រូវបានចែកជូនសមាជិកទាំងអស់ មុនពេលប្រជុំ GDCC រួចហើយផងដែរ ។ លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក យើងអាចពិនិត្យអំពីកិច្ចប្រឹងប្រែងរបស់យើងសម្រាប់ពង្រឹងប្រសិទ្ធភាពនៃយន្តការ GDCC តាម ៣ របៀប គឺ ÷

ទី១- យើងអាចចាត់ទុក GDCC គឺគ្រាន់ជាយន្តការសម្រាប់ការពិភាក្សានិងសម្រាប់ពង្រឹងភាពជាដៃគូ ។ ក្នុងស្មារតីនេះ យើងគ្រាន់តែពិនិត្យជម្រើសនានាសម្រាប់បង្កើនប្រសិទ្ធភាពនៃយន្តការនេះតែប៉ុណ្ណោះ ។

ទី២- យើងអាចពិនិត្យរចនាសម្ព័ន្ធនៃការពិភាក្សាទាំងមូលឱ្យបានពេញលេញ ដោយត្រូវទទួលស្គាល់អំពីភាពចាំបាច់ក្នុងការធានាឱ្យក្រុមការងារបច្ចេកទេសចម្រុះដំណើរការមានប្រសិទ្ធភាពផង និងរក្សាបាននូវទំនាក់ទំនងជាមួយនឹងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាផងដែរ ។ ក្នុងស្មារតីនេះ យើងបានពិនិត្យ និងកែសម្រួលការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះ កាលពីចុងឆ្នាំ២០១០កន្លងមក ហើយយើងកំពុង

គិតគូរអំពីអន្តរកាលក្នុងការឈានឡើងពីវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ដែលជាយន្តការរបស់យើង នាពេលបច្ចុប្បន្ន ទៅ «វេទិកាអភិវឌ្ឍន៍កម្ពុជា» នាពេលអនាគតផងដែរ ។

ទី៣- យើងអាចពិនិត្យបញ្ហាទាំងអស់នេះ នៅពេលយើងពិនិត្យនិងរៀបចំឡើងវិញនូវគោលនយោបាយសម្រាប់គ្រប់គ្រងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលគ្រោងនាដើមឆ្នាំ២០១២ បន្ទាប់ពីវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៤ និងវេទិកាកំពូលលើកទី៤ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិ-បត្តិការ នាចុងឆ្នាំ ២០១១ នេះ ។

លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក

៣- សំណើសំខាន់ៗក្នុងសេចក្តីព្រាងឯកសារស្តីពីការគ្រប់គ្រងកិច្ចប្រជុំ GDCC ត្រូវបានរំលេចក្នុងជំពូកសំខាន់ៗ ចំនួន៣ ដូចខាងក្រោម ÷

- ការឯកភាពលើគោលដៅនៃកិច្ចប្រជុំ GDCC
- ការត្រៀមរៀបចំកិច្ចប្រជុំ GDCC និង
- ការធានាប្រសិទ្ធភាពនៃកិច្ចប្រជុំ GDCC ។

យើងបានទទួលធាតុចូលពីសមាជិកនៃ GDCC សម្រាប់រៀបចំសេចក្តីព្រាងឯកសារនេះ ។ ខ្ញុំសូមអរគុណលោក Qimiao Fan នៃធនាគារពិភពលោក ដែលបានបូកសរុបអនុសាសន៍ទាំងឡាយរបស់សហគមដៃគូអភិវឌ្ឍន៍ ហើយបានផ្តល់មកលេខាធិការដ្ឋានកន្លងមក ។ ទន្ទឹមនេះដែរ ក៏សូមថ្លែងអំណរគុណដល់សហអ្នកសម្របសម្រួលនៃក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សុខដុមនីយកម្មនិងភាពជាដៃគូ ដែលបានគាំទ្រយ៉ាងពេញទំហឹងក្នុងការពិភាក្សារបស់ក្រុមការងារនាខែកុម្ភៈកន្លងមកនេះ ។

៤- ទន្ទឹមនេះដែរ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក៏បានរៀបចំឯកសារសង្ខេបចំនួនមួយទំព័រ ហើយបានចែកជូនសមាជិកទាំងអស់កន្លងមក ។ ឯកសារសង្ខេបនេះបានឆ្លុះបញ្ចាំងអំពីចំណុចសំខាន់ៗដូចតទៅ ÷

៥- ចំពោះគោលដៅនៃកិច្ចប្រជុំ GDCC យើងហាក់ដូចជាបានឯកភាពគ្នាដោយចាត់ទុកថា ÷

ទី១- GDCC គឺជាវេទិកាសម្រាប់ពិភាក្សាកម្រិតគោលនយោបាយ ដោយផ្តោតទៅលើបញ្ហាដែលបានរកឃើញក្នុងកិច្ចប្រជុំ CDCF ហើយដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ ឬបញ្ហាសំខាន់ៗដែលពាក់ព័ន្ធក្នុងកម្រិតម៉ាក្រូ ឬកម្រិតវិស័យ ឬអន្តរវិស័យ ព្រមទាំងក្នុងការដ្ឋានកំណែទម្រង់របស់រាជរដ្ឋាភិបាល ។

ទី២- GDCC គឺជាវេទិកាសម្រាប់តាមដានការអនុវត្តន៍សូចនាកររួមគ្នា - តាមរយៈរបាយការណ៍របស់ក្រុមការងារបច្ចេកទេសចម្រុះ ក៏ដូចជាផ្តោតលើបញ្ហាពិសេស ដូចដែលកិច្ចប្រជុំរបស់យើងថ្ងៃនេះបានផ្តោតទៅលើយុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ជាដើម ។

ទី៣- GDCC គឺជាវេទិកាសម្រាប់ពិនិត្យដោះស្រាយបញ្ហាដែលនៅជាប់ជំពាក់ មិនអាចដោះស្រាយបានក្នុងកម្រិតក្រុមការងារបច្ចេកទេសចម្រុះ ឬបញ្ហាណាដែលមិនស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមការងារបច្ចេកទេសចម្រុះជាក់លាក់ណាមួយ ។

៦- ចំពោះការរៀបចំ GDCC យើងត្រូវផ្អែកលើ ÷

ទី១- ការពិភាក្សានៅ CDCF ពោលគឺសកម្មភាពដែលបានឯកភាពក្នុង CDCF និងសូចនាករតាមដានរួមគ្នា ។ ប៉ុន្តែ យើងក៏រក្សាភាពទន់ភ្លន់ផងដែរ សម្រាប់កំណត់បញ្ហាសម្រាប់ពិភាក្សា ដោយផ្អែកតាមការស្នើឡើងរបស់សមាជិកនៃ GDCC ផងដែរ ។

ទី២- ការរៀបចំរបៀបវារៈគឺជាបញ្ហាសំខាន់ ហើយត្រូវពិភាក្សាគ្នាដើម្បីឆ្លុះបញ្ចាំងទស្សនៈរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ក្នុងរយៈពេលថ្មីៗកន្លងមក ការរៀបចំរបៀបវារៈត្រូវបានកែលំអជាច្រើន ដោយបានអនុវត្តតាមគោលការណ៍នេះ ។ ជាក់ស្តែង របៀបវារៈត្រូវបានផ្តួចផ្តើមដំបូងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ បន្ទាប់មក ត្រូវបានពិភាក្សាជាមួយប្រធានក្រុមការងារ/ ប្រធានលេខាធិការដ្ឋានក្រុមការងារ រួចហើយ ទើបបានពិភាក្សានិងឯកភាពជាមួយនឹងធនាគារពិភពលោក ក្នុងឋានៈជាប្រធានសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍ ដែលត្រូវពិភាក្សាបន្តជាមួយសហគមដៃគូអភិវឌ្ឍន៍ ។

ទី៣- ក្រុមការងារនិងប្រធានសម្របសម្រួលនឹងត្រូវត្រៀមរៀបចំជាមួយគ្នា ។ នេះជាចំណុចដែលត្រូវយកចិត្តទុកដាក់ ព្រោះថាចំណុចខ្លាំងរបស់ GDCC គឺត្រូវផ្អែកជាមូលដ្ឋានលើការងាររបស់ក្រុមការងារ ។

ទី៤- របាយការណ៍ស្តីពីវឌ្ឍនភាពរបស់ក្រុមការងារនិងសូចនាករតាមដានរួមគ្នា ត្រូវបានរៀបចំដោយលេខាធិការដ្ឋានរបស់ GDCC ហើយត្រូវចែកចាយជូនគ្រប់សមាជិករបស់ GDCC ។ កន្លងមក យើងបានទទួលមតិយោបល់តិចតួចលើរបាយការណ៍នេះ ហើយខ្ញុំក៏មិនបានដឹងច្បាស់ថាតើរបាយការណ៍ត្រូវបានពិភាក្សា ឬត្រូវបានប្រើប្រាស់ដល់កម្រិតណាឡើយនៅតាមក្រុមការងារនិមួយៗ ។ ខ្ញុំយល់ថា នេះប្រហែលជាចំណុចមួយ ដែលយើងត្រូវពិនិត្យពីកិច្ចប្រតិបត្តិបច្ចុប្បន្ន ដើម្បីធានាទំនាក់ទំនង និងភាពតភ្ជាប់ការងាររវាងយន្តការទាំង២នេះ ។

ទី៥- ឯកសារទាំងអស់សម្រាប់កិច្ចប្រជុំត្រូវចែកចាយគ្រប់សមាជិកទាំងអស់ មុនកិច្ចប្រជុំយ៉ាងតិចចំនួន ១ សប្តាហ៍ ។

៧- ចំពោះការបង្កើនប្រសិទ្ធភាពនៃកិច្ចប្រជុំ GDCC សេចក្តីព្រាងឯកសារបានលើកសំណើមួយចំនួន ដើម្បីពង្រឹងយន្តការ GDCC ។ ខ្ញុំសូមការអនុញ្ញាតមិនអាចសំណើទាំង១០នេះឡើយ ។ ដូចបានស្នើឡើងក្នុងឯកសារក៏ដូចជាក្នុង Slide បានបង្ហាញ លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក បានជ្រាបអំពីទំនាក់ទំនងរបស់ GDCC ជាមួយនឹងក្រុមការងារបច្ចេកសេចម្រុះ និងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ។

លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក

៨- សរុបសេចក្តីមក យើងទាំងអស់គ្នា ជានិច្ចជាកាល បានយកចិត្តទុកដាក់ ពិនិត្យឡើងវិញការងាររបស់យើង ហើយបានស្វែងរកវិធីថ្មីៗសំដៅបង្កើនប្រសិទ្ធភាពនៃយន្តការសម្របសម្រួលGDCC នេះ ។ ខ្ញុំសូមស្នើលោកជំទាវ ឯកឧត្តម លោកស្រី អស់លោក មេត្តាផ្តល់យោបល់ក្នុងន័យស្ថាបនាលើសំណើទាំងនេះ និងសូមស្វាគមន៍ចំពោះមតិយោបល់របស់លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក ។

សូមអរគុណ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាននៃកិច្ចប្រជុំ GDCC និងសូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់ លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក ។